# សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦

# សង្គមស៊ីវិលអំពាវនាវឱ្យអាជ្ញាធរបញ្ឈប់ជាបន្ទាន់នូវការយាយីដល់អ្នកការពារសិទ្ធិមនុស្ស

យើងខ្ញុំ ជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមថ្កោលទោសចំពោះការកោះហៅ និងសាកសួរទៅលើមន្ត្រីអង្គការសង្គមស៊ីវិលដែលបានធ្វើសកម្មភាពសមស្រប និងត្រឹមត្រូវតាមច្បាប់ក្នុងការការពារសិទ្ធិមនុស្ស។ នេះជាការអនុវត្តដោយបំពានរបស់អង្គភាពប្រឆាំងអំពើពុករលួយ ("អ.ប.ព") ដែលត្រូវបានប្រើប្រាស់ដើម្បីគំរាមកំហែងទៅលើសង្គមស៊ីវិល។

មន្ត្រីអង្គការសង្គមស៊ីវិលចំនួនប្រាំពីររូបត្រូវបាន អ.ប.ព សាកសួរក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះទាក់ទិនទៅនឹងពាក្យបណ្តឹងមួយប្តឹងដោយកញ្ញា ខុំ ចាន់តារ៉ាទី ហៅស្រីមុំ ដែលត្រូវបានគេចោទថាជានារីកំណាន់របស់លោក កឹម សុខា អនុប្រធានគណបក្សជំទាស់។ អ្នកទាំងនោះរួមមានបុគ្គលិករបស់សមាគមអាដហុកប្រាំនាក់ផងដែរ ដូចជា លោក នី សុខា (ប្រធានផ្នែកសិទ្ធិមនុស្ស) លោក ណៃ វ៉ង់ដា (អនុប្រធានផ្នែកសិទ្ធិមនុស្ស) លោក យី សុខសាន្ត (មន្ត្រីស៊ើបអង្កេតនិងឃ្លាំមើលសិទ្ធិមនុស្ស) អ្នកស្រី ទ្រី ឈួន (មេធាវី) និង អ្នកស្រី លឹម មុនី (អនុប្រធានផ្នែកសិទ្ធិស្ត្រី) ព្រមទាំងលោកស្រី ធីតា ឃឹះ នាយិកាអង្គការសីលការ និងលោក នី ចរិយា អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(និងជាអតីតប្រធានផ្នែកសិទ្ធិមនុស្សនៃសមាគមអាដហុក)។ លោក សឿន សាលី មន្ត្រីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ក៏ត្រូវបាន អ.ប.ព កោះហៅពាក់ព័ន្ធទៅនឹងករណីដូចគ្នានេះដែរ ប៉ុន្តែដោយសារតែលោកមានអភ័យឯកសិទ្ធិជាសមាជិកមួយរូបរបស់អង្គការសហប្រជាជាតិ ដូច្នេះលោកមិនបានចូលខ្លួនបង្ហាញនៅចំពោះមុខ អ.ប.ព ឡើយ។

តួនាទីរបស់ អ.ប.ព ក្នុងការកោះហៅមន្ត្រីអង្គការសង្គមស៊ីវិល ដើម្បីសាកសួរដោយសារតែធ្វើសកម្មភាពស្របច្បាប់ជាប់ពាក់ព័ន្ធនឹងករណីរសើបនយោបាយនោះគឺមិនសមហេតុផលឡើយ ហើយនេះគឺជាការគំរាមកំហែងនិងការយាយីទៅលើអ្នកការពារសិទ្ធិមនុស្ស។ ម្យ៉ាងទៀត ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយតម្រូវឱ្យ អ.ប.ព អនុវត្តតួនាទីរបស់ខ្លួនដោយឯករាជ្យ មិនពាក់ព័ន្ធក្នុងរឿងនយោបាយ។ ប៉ុន្តែនៅដើមសប្តាហ៍នេះ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា ("ប្រ.ជ") ត្រូវបានរាយការណ៍ថាបានថ្លែងថាការតែងតាំងកូនប្រុសរបស់ប្រធាន អ.ប.ព លោក ឱម យ៉ិនទៀង គឺជារឿងធម្មតាហើយថារដ្ឋាភិបាលនឹងតែងតាំងតែបុគ្គលិកដែលមានសមត្ថភាពរបស់ ប្រ.ជ ប៉ុណ្ណោះ។

ការអនុវត្តក្នុងការស៊ើបអង្កេតនេះបង្ហាញថា អ.ប.ព មិនបានធ្វើការងារជាអាទិភាពក្នុងការលុបបំបាត់អំពើពុករលួយជាទូទៅនោះឡើយ ផ្ទុយមកវិញបែរជាបំពេញការងាររំលោភទៅលើអំណាចរបស់ខ្លួនទៅវិញ តាមរយៈការ

បង្ក្រាបទៅលើសង្គមស៊ីវិលនិងកំណត់មុខសញ្ញាទៅលើគណបក្សជំទាស់។ នេះជាការអនុវត្តមិនត្រឹមត្រូវទាល់តែសោះសម្រាប់ស្ថាប័ននេះក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើសង្គមស៊ីវិលនិងអ្នករិះគន់រដ្ឋាភិបាល។ ប្រទេសកម្ពុជាជាប់ឈ្មោះជាប្រទេសពុករលួយបំផុតនៅក្នុងតំបន់អាស៊ី[1] ក្នុងបរិបទនេះ អ.ប.ព គួរតែត្រូវខិតខំលុបបំបាត់អំពើពុករលួយជំនួសវិញ ជាជាងធ្វើការ យាយីទៅលើមន្ត្រីអង្គការសង្គមស៊ីវិលដែលធ្វើការងារដើម្បីលើកកម្ពស់សិទ្ធិមនុស្ស។

អ.ប.ព គឺជាស្ថាប័នចុងក្រោយបង្អស់ក្នុងចំណោមស្ថាប័នជាច្រើនដែលធ្វើការស៊ើបអង្កេតក្នុងករណីនេះ។ ការអនុវត្តតួនាទីមិនត្រឹមត្រូវរបស់នគរបាលប្រឆាំងភេរវកម្មក្នុងការសួរចម្លើយកញ្ញា ខុំ ចាន់តារ៉ាទី នៅតែស្ថិតនៅក្នុងភាពមិនច្បាស់លាស់នៅឡើយ។ កញ្ញា ត្រូវបានសួរចម្លើយដោយមិនសមហេតុផលក្នុងពេលស៊ើបអង្កេតលើបណ្តឹងបរិហារកេរ្តិ៍ធ្វើឡើងដោយសកម្មជននយោបាយកញ្ញា ធី សុវណ្ណថា ទាក់ទិនទៅនឹងករណីនេះដែលមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់អង្គភាពប្រឆាំងភេរវៈកម្មទាល់តែសោះ។ ករណីនេះធ្វើឡើងក្នុងអំឡុងពេលយុទ្ធនាការរបស់ក្រុមយុវជនប្រឆាំងនឹងលោក កឹម សុខា។

ជាការឆ្លើយតបទៅនឹងស្ថានភាពដ៏គួរឱ្យព្រួយបារម្ភនាពេលបច្ចុប្បន្ននេះ លោក ធន សារាយ ប្រធានសមាគមអាដហុកបានថ្លែងថា «សមាគមអាដហុកមិនបានធ្វើសកម្មភាពណាមួយប៉ះពាល់ដល់សមត្ថកិច្ចរបស់ អ.ប.ព ឡើយ ព្រោះថារឿងនេះមិនមែនជាករណីពុករលួយ។ សមាគមអាដហុកគ្រាន់តែផ្តល់ជំនួយនិងការពារជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សដែលមករកជំនួយដល់ការិយាល័យរបស់ខ្លួនតែប៉ុណ្ណោះ។ នេះគឺជាសកម្មភាពដែលសមាគមអាដហុកបានធ្វើ។ សមាគមអាដហុកមិនបានធ្វើអ្វីខុសឆ្គងឡើយ»។

លោកស្រី ណាលី ពីឡូក នាយិកាអង្គការលីកាដូ មានប្រសាសន៍ថា «ការអូសទាញបុគ្គលិកអង្គការសង្គមស៊ីវិលដែលមិនពាក់ព័ន្ធឱ្យចូលទៅក្នុងករណីនេះគឺជាឧទាហរណ៍មួយផ្សេងទៀតនៃភាពចន្លោះប្រហោងនៃប្រព័ន្ធយុត្តិធម៌កម្ពុជា ដែលមិនមែនគាបសង្កត់តែទៅលើអ្នករិះគន់រដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអ្នកដែលគាំទ្រពួកគេផងដែរ»។

នៅថ្ងៃទី២៥ ខែមេសា អ្នកវិភាគនយោបាយឯករាជ្យ លោក អ៊ូ វីរៈ ត្រូវបានកំណត់មុខសញ្ញាផងដែរដោយសារលោកបានថ្លែងមតិទាក់ទិនទៅនឹងករណីរបស់កញ្ញាចាន់តារ៉ាទី។ ជាការឆ្លើយតប លោក សុខ ឥសាន អ្នកនាំពាក្យ ប្រ.ជ បានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងលោក អ៊ូ វីរៈ ពីបទបរិហាកេរ្តិ៍ជាសាធារណៈ។ ពាក្យបណ្តឹងនោះទាមទារសំណងជម្ងឺចិត្តជាទឹកប្រាក់ចំនួន ៤០០.០០០.០០០ រៀល (ប្រមាណ១០០.០០០ដុល្លាអាមេរិក) ដែលអាចជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំ ក្នុងករណីមិនបង់ប្រាក់តាមការបង្គាប់។ ពាក្យបណ្តឹងនោះធ្វើឡើងក្រោយពីមានការលើកឡើងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលថា ប្រ.ជ នឹងចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នក

---

[1] យោងតាមសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយឆ្នាំ២០១៥ របស់អង្គការតម្លាភាពកម្ពុជា។

វិភាគនយោបាយណាដែលបង្ខូច "កិត្តិយស និងកិត្តិសព្ទ" របស់គណបក្សកាន់អំណាច។ មតិយោបល់របស់លោក អ៊ូ វីរៈ ធ្វើឡើងនៅក្នុងវិសាលភាពនៃការបញ្ចេញមតិដែលធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក មានប្រសាសន៍ថា «ការកំណត់មុខសញ្ញាទៅលើលោក អ៊ូ វីរៈ ស្របពេលជាមួយនឹងការសួរចម្លើយបុគ្គលិកអង្គការសង្គមស៊ីវិលគឺមិនមែនជារឿងចៃដន្យឡើយ។ សង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា កំពុងស្ថិតនៅក្រោមការវាយប្រហារយ៉ាងធ្ងន់ធ្ងរ ហើយស្ថានការណ៍នេះកំពុងតែយ៉ាប់យ៉ឺនឡើងព្រោះការបោះឆ្នោតកាន់តែខិតជិតមកដល់។ ប៉ុន្តែយុទ្ធសាស្ត្រនៃការបំភិតបំភ័យទាំងនេះនឹងមិនមានប្រសិទ្ធភាពនោះទេ។ យើងរួមសាមគ្គីគ្នាប្រឈមតទល់ទៅនឹងការគំរាមកំហែងនេះ»។

សកម្មភាពមិនសមរម្យរបស់ អ.ប.ព គឺជាសកម្មភាពថ្មីបំផុតក្នុងយុទ្ធនាការដែលកើតឡើងក្នុងការបំបិទលំហសង្គមស៊ីវិលនៅមុនការបោះឆ្នោតនាពេលខាងមុខ។ អង្គការសង្គមស៊ីវិលនិងបុគ្គលិករបស់ខ្លួនប្រឈមនឹងការយាយី និងអំពើហិង្សាជាបន្តបន្ទាប់មកលើសេរីភាពមូលដ្ឋានរបស់ពួកគេ ខណៈដែលការអនុម័តច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលបានវាយប្រហារដោយផ្ទាល់មកលើសង្គមស៊ីវិល។

យើងខ្ញុំ សូមអំពាវនាវដល់អង្គភាពប្រឆាំងអំពើពុករលួយឱ្យទម្លាក់ការស៊ើបអង្កេតរបស់ខ្លួនមកលើមន្ត្រីអង្គការសង្គមស៊ីវិលដែលគ្រាន់តែបំពេញការងាររបស់ខ្លួនដើម្បីការពារជនរងគ្រោះពីការរំលោភបំពានសិទ្ធិមនុស្សប៉ុណ្ណោះ។ ជាងនេះទៅទៀត យើងខ្ញុំសូមអំពាវនាវដល់សាលាដំបូងរាជធានីភ្នំពេញ ប្រានចោលពាក្យបណ្តឹងប្រឆាំងនឹងលោក អ៊ូ វីរៈ ស្របតាមកាតព្វកិច្ចរបស់ខ្លួនក្រោមរដ្ឋធម្មនុញ្ញកម្ពុជានិងច្បាប់អន្តរជាតិ។

**អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ រួមមាន៖**

| **ល.រ** | **នាមអង្គការសង្គមស៊ីវិល** | **នាមអ្នកចូលរួម** | **លេខទំនាក់ទំនង** |
|---|---|---|---|
| ១ | *សម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA Cambodia)* | *លោក សន ជ័យ* | 012 445 642 |
| ២ | *អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)* | *លោកស្រី ព្រំ ផល្លីភួង* | 012 307 027 |
| ៣ | *សង់ត្រាល់ (CENTRAL)* | *លោក មឿន តុលា* | 093 556 643 |
| ៤ | *មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)* | *លោកស្រី ចក់ សុភាព* | 011 943 213 |
| ៥ | *គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ~សមាគមការពារសិទ្ធិមនុស្សកម្ពុជា* | *លោក សួន ប៊ុនស័ក្តិ* | 092 344 357 |

| | | | |
|---|---|---|---|
| | (CHRAC) | | |
| ៦ | សហភាពការងារកម្ពុជា (CLC) | លោក អាត់ ធន់ | 012 998 906 |
| ៧ | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO) | អ្នកនាង ណាលី ពីឡូក | 012 803 650 |
| ៨ | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) | លោក ញឹក សារិន | 012 800 561 |
| ៩ | សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (CISA) | លោក ហ៊ឹម យន់ | 012 947 022 |
| ១០ | សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) | លោក ថេង សាវឿន | 015 225 088 |
| ១១ | គណៈកម្មាធិការ ដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) | លោក គល់ បញ្ញា | 012 942 017 |
| ១២ | Diakonia | អ្នកស្រី ណេវ៉ា ជួន | 012 465 117 |
| ១៣ | បណ្តាញយុវជនកម្ពុជា (CYN) | លោក ទឹម ម៉ាឡៃ | 017 990 689 |
| ១៤ | អង្គការសមធម៌កម្ពុជា (EC) | លោក អៀង វុទ្ធី | 012 791 700 |
| ១៥ | អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) | លោកស្រី រស់ សុភាព | 012 627 857 |
| ១៦ | ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) | លោក សៀ ភារម្យ | 012 852 325 |
| ១៧ | សមាគម ឥន្ទ្រទេវី (IDA) | លោកស្រី ឌី វដ្ឋា | 012 897 161 |
| ១៨ | សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) | លោក វន់ ពៅ | 012 534 796 |
| ១៩ | ជំនួយផ្នែកច្បាប់កម្ពុជា (LAC) | លោក វុន សាវ៉ាយ | 012 838 341 |
| ២០ | អង្គការមាតាធម្មជាតិ (MN) | Mr. Alejandro Gonzalez-Davidson. | NA |
| ២១ | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព (PDP-Center) | លោក យ៉ង់ គឹមអេង | 016 828 211 |
| ២២ | សមាគមជាងត្នោត (STT) | លោក អ៊ី សារុំ | 012 836 533 |
| ២៣ | អង្គការស្ត្រីខ្មែរ (SKO) | លោកស្រី អរុណ រស្មី | 012 236 653 |
| ២៤ | សហព័ន្ធសហជីពកម្មករសំណង់និងព្រៃឈើកម្ពុជា (BWTUC) | លោក វ៉ាន់ ថុល | 012 752 617 |

| | | | |
|---|---|---|---|
| ២៥ | ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT) | កញ្ញា ស្រី សុជាវី | 017 990 371 |
| ២៦ | សហព័ន្ធបុគ្គលិកទេសចរកម្ពុជា (CTSWF) | លោក ម៉ម រិទ្ធី | 012 411 755 |
| ២៧ | អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD) | លោកស្រី ស៊ុំ សាម៉ុន | 012 646 955 |